# Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយជាបន្ទាន់

# វេទិកាអ្នកពាក់ព័ន្ធ ជជែកវែកញែកពីសំណើគម្រោងប៉ាក់ឡាយ លើកជាអនុសាសន៍អំពីជំហានសម្រាប់ពង្រឹងការរៀបចំផែនការអាងទន្លេក្នុងតំបន់ទន្លេមេគង្គ

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០១៨** – វេទិកាអ្នកពាក់ព័ន្ធថ្នាក់តំបន់ រយៈពេលពីរថ្ងៃ ស្ដីពីសំណើគម្រោងវារីអគ្គិសនីប៉ាក់ឡាយ និងគំនិតផ្តួចផ្តើមដែលកំពុងអនុវត្តផ្សេងទៀត ត្រូវបានបញ្ចប់នៅថ្ងៃនេះ។ វេទិកា ដែលរៀបចំដោយគណៈកម្មការទន្លេមេគង្គ (Mekong River Commission) ហៅកាត់ថា MRC នេះ មានអ្នកចូលរួមប្រមាណជា ១៦០ នាក់ មកពីក្រុមអ្នកពាក់ព័ន្ធនានា ដូចជា សង្គមស៊ីវិល ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សាស្រាវជ្រាវ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ អ្នកចូលរួម បានលើកឡើងពីការព្រួយបារម្ភនានា និងបានរួមគ្នាផ្តល់អនុសាសន៍ ដើម្បីពង្រឹងការរៀបចំផែនការអាងទន្លេ និងការគ្រប់គ្រងបរិស្ថានក្នុងតំបន់ទន្លេមេគង្គ។

លោក អាន ពេជ្រហត្ថដា (An Pich Hatda) មន្ត្រីទទួលបន្ទុក និងនាយកផ្នែកផែនការនៃលេខាធិការដ្ឋាន MRC មានប្រសាសន៍ថ្លែងអំណរគុណដល់អ្នកចូលរួម កាលពីថ្ងៃព្រហស្បតិ៍ថា "MRC ជឿជាក់ថា ការបញ្ចូល និងការគិតគូរពីទស្សនៈយល់ឃើញ និងផលប្រយោជន៍ផ្សេងៗគ្នារបស់ភាគីពាក់ព័ន្ធ ជួយពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកទឹកក្នុងតំបន់អាងទន្លេនេះ ហើយនេះគឺជាអាទិភាពខ្ពស់បំផុតនៃកិច្ចខិតខំប្រឹងប្រែងដើម្បីឈានទៅសម្រេចចក្ខុវិស័យរបស់យើង។ យើង មិនអាចដឹងបានពីការព្រួយបារម្ភរបស់អ្នកឡើង ប្រសិនបើអ្នកមិនលើកឡើង។ យើងក៏ពុំអាចបំពេញតម្រូវការរបស់អ្នកឡើយ ប្រសិនបើយើងមិនដឹង និងមិនយល់ ថាតើតម្រូវការទាំងនោះជាអ្វីនោះ។"

នៅថ្ងៃទីមួយនៃវេទិកានេះ អ្នកចូលរួម មានឱកាសពិនិត្យនិងពិភាក្សាលើបញ្ហានានាទាក់ទងនឹងជលសាស្ត្រ ជលគតិវិជ្ជា ដីល្បាប់ សុវត្ថិភាពទំនប់ នាវាចរណ៍ គុណភាពទឹក ធនធាននេសាទ និងសង្គមសេដ្ឋកិច្ច នៃសំណើគម្រោងវារីអគ្គិសនីប៉ាក់ឡាយ (Pak Lay) ដែលអាចផលិតអគ្គិសនីបាន ៧៧០ មេហ្គាវ៉ាត់។ បន្ទាប់ពីការពិភាក្សារួចមក អ្នកចូលរួមបានផ្តល់នូវអនុសាសន៍ជាច្រើន សម្រាប់របាយការណ៍ពិនិត្យបច្ចេកទេសរបស់គម្រោង ដែលនឹងត្រូវរៀបចំដោយលេខាធិការដ្ឋាន MRC។

ជាឧទាហរណ៍ អ្នកចូលរួមបានលើកស្នើថា វិធានប្រតិបត្តិការ ដែលរៀបចំឡើងសម្រាប់ទំនប់វារីអគ្គិសនីផ្សេងទៀតដែលស្ថិតនៅតាមដងទន្លេមេ គួរយកមកធ្វើការពិចារណា សម្រាប់ប្រតិបត្តិការទំនប់ប៉ាក់ឡាយ។ មានការលើកស្នើផងដែរថា លេខាធិការដ្ឋាន MRC និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៅថ្នាក់ជាតិ គួរធ្វើការប្រមូលទិន្នន័យអំពីប្រភេទត្រីនានា ដើម្បីជាជំនួយដល់ការកែលម្អការសាងសង់ច្រកសម្រាប់ត្រីផ្លាស់ទី ដោយហេតុថា មានការលំបាកនានា ដែលកើតឡើងដោយសារការសាងសង់ទំនប់

បន្ទាក់គ្នាក្នុងដងទន្លេមេនៃទន្លេមេគង្គ។ បន្ថែមពីនេះទៀត ក៏មានការផ្តល់អនុសាសន៍ឱ្យធ្វើការពិចារណាឱ្យបានច្បាស់លាស់ពីសមាសភាគយេនឌ័រ ក្នុងគម្រោងដែលស្នើឡើងនេះផងដែរ។

អ្នកពាក់ព័ន្ធផ្សេងទៀត បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយអនឡាញ ដើម្បីលើកឡើងពីការព្រួយបារម្ភរបស់ខ្លួន ជាពិសេស ពួកគេបានកត់សម្គាល់ថា ផ្នែកមួយចំនួននៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមឆ្លងដែន និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសរុប (TBSEIA/CIA) នៃគម្រោងប៉ាក់ឡាយ ហាក់បីដូចជាស្រដៀងគ្នានឹងការវាយតម្លៃហេតុប៉ះពាល់នៃគម្រោងប៉ាក់បេង (Pak Beng) ដែរ។ ក៏មានការលើកឡើងនូវសេចក្តីព្រួយបារម្ភផងដែរ ថាតើក្រុមហ៊ុនអភិវឌ្ឍន៍គម្រោង បានធ្វើការពិចារណាពីគោលនយោបាយ និងការសិក្សា ដែលធ្វើឡើងកាលពីពេលថ្មីៗនេះដោយ MRC ក្នុងការវាយតម្លៃរបស់ពួកគេដែរឬទេ។

លោក អាន ពេជ្រហត្ថដា មន្ត្រីទទួលបន្ទុក និងនាយកផ្នែកផែនការនៃលេខាធិការដ្ឋាន MRC បានពន្យល់ទៀតថា "ក្នុងការពិនិត្យស៊ីជម្រៅលើឯកសារទាំងនេះ ក្នុងអំឡុងដំណើរការពិគ្រោះយោបល់ជាមុននេះ យើងនឹងធ្វើការពិនិត្យលើកម្រិតនៃភាពស្រដៀងគ្នា រវាងការវាយតម្លៃគម្រោងប៉ាក់ឡាយ និងប៉ាក់បេង ក៏ដូចជាកំណត់ពីចំណុចសម្រាប់ធ្វើការកែលម្អការវាយតម្លៃទាំងនេះ តាមយៈធ្វើឱ្យមានការបញ្ចូលទិន្នន័យនិងព័ត៌មានថ្មីៗ។ ក្រុមការងាររបស់យើង នឹងបញ្ចូលលទ្ធផលរកឃើញរបស់យើង ទៅក្នុងរបាយការណ៍ពិនិត្យបច្ចេកទេស ហើយនឹងរំលេចឱ្យឃើញថាតើចំណុចខ្វះខាតទាំងនេះ អាចបង្កផលប៉ះពាល់ដល់ភាពសមហេតុសមផល និងភាពត្រឹមត្រូវនៃការវាយតម្លៃគម្រោងនេះដែរឬទេ។"

អនុសាសន៍របស់តួអង្គពាក់ព័ន្ធសំខាន់ៗទាំងអស់ ត្រូវបានកត់ត្រាទុក ក៏ដូចជានឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍ស្តីពីវេទិកានេះ ដែលបន្ទាប់មកនឹងត្រូវយកទៅធ្វើការពិចារណា និងឆ្លុះបញ្ចាំងក្នុងរបាយការណ៍ពិនិត្យបច្ចេកទេស។ របាយការណ៍ពិនិត្យបច្ចេកទេស នឹងបញ្ចូលការវាយតម្លៃបច្ចេកទេសលើសំណើគម្រោងនេះ ហើយរបាយការណ៍នេះទៀតសោធន៍ នឹងត្រូវដាក់ជូនប្រទេសជាសមាជិករបស់ MRC ជាពិសេសប្រទេសដែលលើកស្នើគម្រោង ដើម្បីឱ្យមានការពិចារណា និងដាក់បញ្ចូលទៅក្នុងសេចក្តីថ្លែងការណ៍រួម និងរបាយការណ៍សកម្មភាពរួម។

លោកស្រី ប៊ូខាំ វ៉ាជិត (Bounkham Vorachit) អនុរដ្ឋមន្ត្រីក្រសួងធនធានធម្មជាតិ និងបរិស្ថានឡាវ មានប្រសាសន៍ក្នុងការថ្លែងសុន្ទរកថាបើកវេទិកានេះថា "ប្រទេសឡាវ ជានិច្ចកាល តែងផ្តល់សារៈសំខាន់ និងយកចិត្តទុកដាក់ជាពិសេសចំពោះគោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ និង នីតិវិធីនិងគោលការណ៍ណែនាំដទៃទៀតរបស់ MRC។ ការឆ្លើយតបចំពោះបញ្ហាប្រឈមនៃការអភិវឌ្ឍប្រកបដោយចីរភាព នឹងមិនអាចធ្វើទៅបានឡើយ ប្រសិនបើពុំមានការគាំទ្រដ៏ច្រើន និងកិច្ចសហប្រតិបត្តិការពីអ្នកពាក់ព័ន្ធរបស់យើងនោះ។"

នៅថ្ងៃទីពីរនៃវេទិកានេះ អ្នកចូលរួម ក៏មានឱកាសស្តាប់ព័ត៌មានបច្ចុប្បន្នភាព និងផ្តល់យោបល់អំពីគំនិតផ្តួចផ្តើមដែលកំពុងបន្តអនុវត្តដោយ MRC។ បញ្ហាសំខាន់ៗ ដែលត្រូវបានលើកឡើង រួមមានៈ ការធ្វើបច្ចុប្បន្នភាព និងការពិភាក្សាពីផែនការសកម្មភាពរួម សម្រាប់គម្រោងវារីអគ្គិសនីប៉ាក់បេង ការពិនិត្យលើការផ្លាស់ប្តូរ និងការសាងសង់ទំនប់សៃយ៉ាប៊ូរី (Xayaburi) និង ការធ្វើបច្ចុប្បន្នភាពនៃការ

រៀបចំការណែនាំស្តីពីការសាងសង់បឋមសម្រាប់ទំនប់ ដែលលើកស្នើឡើងនៅដងទន្លេមេគង្គក្នុងអាងទន្លេមេគង្គក្រោម។

វេទិកានេះយល់ថា គំនិតផ្តួចផ្តើមកែលម្អការគ្រប់គ្រងការរៀបចំផែនការអាងទន្លេមេទាំងនេះ គឺជាគំនិតផ្តួចផ្តើម ដែលកើតចេញពីកិច្ចពិគ្រោះយោបល់របស់តួអង្គពាក់ព័ន្ធ និងការរួមចំណែករបស់តួអង្គពាក់ព័ន្ធ ក្នុងដំណើរការពិគ្រោះយោបល់ជាមុនកន្លងមក។

តួយ៉ាង ដំណើរការពិគ្រោះយោបល់ជាមុនសម្រាប់ទំនប់វារីអគ្គិសនីសៃយ៉ាប៊ូរី (Xayaburi) ដនសាហុង (Don Sahong) និងប៉ាក់បេង (Pak Beng)បានបង្ហាញពីភាពចាំបាច់ ដើម្បីធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រវារីអគ្គិសនីទូទាំងតំបន់អាងទន្លេ និងគោលការណ៍ណែនាំស្តីពីការសាងសង់ទំនប់ ដែលលើកស្នើឡើងលើដងទន្លេមេនៃទន្លេមេគង្គ ដែលរៀបចំដោយ MRC។ ព័ត៌មានបច្ចុប្បន្នភាពទាំងនេះ មានគោលបំណងជួយឱ្យរដ្ឋជាសមាជិក ពង្រីកផលប្រយោជន៍ក្រៅវង្វង់ព្រំដែនប្រទេសរបស់ខ្លួន និង កាត់បន្ថយផលប៉ះពាល់ឆ្លងដែនអវិជ្ជមានឱ្យនៅតិចជាអប្បបរមា ហើយស្របពេលជាមួយគ្នានេះផ្តល់ការគាំទ្រដល់សន្តិសុខទឹក ស្បៀង និងថាមពល។

នៅក្នុងវេទិការនេះ ក៏មានការបង្ហាញផងដែរថា ការធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រនេះបានបញ្ចប់ពាក់កណ្តាលហើយ ខណៈពេលដែលឯកសារណែនាំវិញ កំពុងស្ថិតនៅក្នុងការពិនិត្យលើកចុងក្រោយដោយប្រទេសជាសមាជិក MRC។

វេទិកាអ្នកពាក់ព័ន្ធថ្នាក់តំបន់នេះ ជាការបំពេញបន្ថែមលើកិច្ចពិគ្រោះយោបល់តាមប្រទេសនីមួយៗ និង ផ្តល់លទ្ធភាពដល់តួអង្គពាក់ព័ន្ធ ដែលពុំមានឱកាសចូលរួមក្នុងកិច្ចប្រជុំក្នុងប្រទេស ឱ្យលើកឡើងពីការព្រួយបារម្ភរបស់ពួកគេ និង ស្វែងយល់បន្ថែមទៀតពីគម្រោងដែលលើកស្នើឡើង ក៏ដូចជា ដំណើរការពិគ្រោះយោបល់ជាមុននេះ។

នេះជាលើកទីបួនហើយ ដែល MRC បានរៀបចំកិច្ចពិគ្រោះយោបល់ជាមុន ក្រោមនីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (Procedures for Notification, Prior Consultation and Agreement) ហៅកាត់ថា PNPCA ដូចជាសម្រាប់គម្រោងវារីអគ្គិសនីសៃយ៉ាប៊ូរី ដែលអាចផលិតថាមពលអគ្គិសនីបាន ១.២៨៥ មេហ្គាវ៉ាត់ គម្រោងវារីអគ្គិសនីដនសាហុង ដែលអាចផលិតថាមពលអគ្គិសនីបាន ២៤០ មេហ្គាវ៉ាត់ និង គម្រោងវារីអគ្គិសនីប៉ាក់បេង ដែលអាចផលិតថាមពលបាន ៩១២ មេហ្គាវ៉ាត់។

កិច្ចពិគ្រោះយោបល់ជាមុនស្តីពីគម្រោងវារីអគ្គិសនីប៉ាក់ឡាយ បានចាប់ផ្តើមជាផ្លូវការកាលពីថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៨ ហើយនឹងបន្តរហូតដល់ខែ មីនា ឆ្នាំ ២០១៩។ នៅពេលនោះ ក្រុមការងារនៃគណៈកម្មាធិការចម្រុះ (Joint Committee Working Group) ដែលជាស្ថាប័នប្រឹក្សាបច្ចេកទេសរបស់ MRC នឹងធ្វើការជជែកពិភាក្សាពីអនុសាសន៍នានា សម្រាប់ដាក់ជូនគណៈកម្មាធិការចម្រុះរបស់ MRC ដែលជាស្ថាប័នអនុវត្តគោលនយោបាយ មានសមាសភាពជាតំណាងមកពីប្រទេសជាសមាជិតទាំងបួនរបស់ MRC។ ដំណើរការពិគ្រោះយោបល់ជាមុននេះ ជាធម្មតា ត្រូវការពេលប្រាំមួយខែ ប៉ុន្តែអាចពន្យារពេលបន្ថែមបាន ប្រសិនបើគណៈកម្មាធិការចម្រុះយល់ព្រម។

វេទិកាពិគ្រោះយោបល់ថ្នាក់តំបន់បន្ទាប់សម្រាប់សំណើរគម្រោងវារីអគ្គិសនីប៉ាក់ឡាយ នឹងធ្វើឡើងនៅពាក់កណ្តាលខែមករា នៅឆ្នាំក្រោយ។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

-**ចប់**-

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក មាស សុភក្ត្រ
មន្ត្រីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទ៖ +856-21-263263 ភ្ជាប់បន្ត 4070
ទូរសព្ទដៃ៖ +856-20-92479737

###